# ការណែនាំវ៉ាក់សាំងជំងឺ COVID-19 ថ្មីសម្រាប់កុមារអាយុ 6 ខែ - 4 ឆ្នាំ



វ៉ាក់សាំងជំងឺ COVID-19 ថ្មីឆ្នាំ 2023-2024 អាចការពារកុមារតូចៗកុំឱ្យឈឺធ្ងន់ធ្ងរ ចូលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងស្លាប់ដោយសារជំងឺ COVID-19។ ការស្រាវជ្រាវបានបង្ហាញថា ទោះបីវ៉ាក់សាំងជំងឺ COVID-19 នៅតែមានប្រសិទ្ធភាព ក៏វាអាចនឹងថមថយប្រសិទ្ធភាព ក្នុងការការពារបន្តិចម្តងៗដែរ។

***ការចាក់វ៉ាក់សាំងជំងឺ COVID-19 ឱ្យទាន់សភាពការណ៍នៅតែជាវិធីដ៏មានប្រសិទ្ធ ភាពបំផុត ដើម្បីបន្ត ការការពារនេះ។***

សូមមើលតារាងខាងក្រោម ដើម្បីដឹងពីចំនួនដូសដែលកូនរបស់អ្នកត្រូវការដើម្បីចាក់វ៉ាក់សាំងជំងឺ COVID-19 ទាន់សភាពការណ៍។

| *យីហោវ៉ាក់សាំង* | *អាយុ* | *ដូសសម្រាប់កុមារមិនទាន់ចាក់វ៉ាក់សាំង* | *កុមារបានចាក់វ៉ាក់សាំងជំងឺ COVID-19 ពីមុន* |
|---|---|---|---|
| ***Pfizer*** | 6 ខែ – 4 ឆ្នាំ | **ដូសទី 1៖** វ៉ាក់សាំងថ្មីឆ្នាំ 2023-2024។<br>**ដូសទី 2៖** វ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសទី 1 បាន 3-8 សប្តាហ៍។<br>**ដូសទី 3៖** វ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសទី 2 យ៉ាងតិច 8 សប្តាហ៍។ | **បានចាក់ 1 ដូសពីមុន៖**<br>ដូសទី 2 នៃវ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសដំបូង 3-8 សប្តាហ៍។<br>ដូសទី 3 ក្រោយចាក់ដូសទី 2 បាន 8 សប្តាហ៍ វ៉ាក់សាំងថ្មីឆ្នាំ 2023-2024។<br>**បានចាក់ 2 ដូសឡើងទៅ៖**<br>1 ដូសនៃវ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយដូសចុងក្រោយយ៉ាងតិច 8 សប្តាហ៍។ |
| ***Moderna*** | 6 ខែ – 4 ឆ្នាំ | **ដូសទី 1៖** វ៉ាក់សាំងថ្មីឆ្នាំ 2023-2024។<br>**ដូសទី 2៖** វ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសទី 1 បាន 4-8 សប្តាហ៍ | **បានចាក់ 1 ដូសពីមុន៖**<br>1 ដូសនៃវ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសចុងក្រោយបាន 4-8 សប្តាហ៍។<br>**បានចាក់ 2 ដូសឡើងទៅ៖**<br>1 ដូសនៃវ៉ាក់សាំងថ្មីឆ្នាំ 2023-2024 ក្រោយចាក់ដូសចុងក្រោយបាន 4-8 សប្តាហ៍។ |
| ***Novavax*** | Novavax មិនផ្តល់ជូនសម្រាប់អ្នកដែលមានអាយុក្រោម 12 ឆ្នាំទេ។ | | |

*ប្រសិនបើអ្ន កមានប្រព័ន្ធ ភាពស៊ាំចុះខ្សោយកម្រិតមធ្យមឬធ្ង ន់ធ្ង រ នោះគោលការណ៍ណែនាំនឹងមានភាពខុសគ្នា ។*

**បុគ្គលដែលបានឆ្លងមេរោគ SARS-CoV-2 ថ្មីៗនេះអាចពិចារណា**ពន្យារពេលចាក់ដូសវ៉ាក់សាំងជំងឺ COVID-19 ត្រឹម 3 ខែចាប់ពីពេលចេញរោគសញ្ញា ឬធ្វើតេស្តឃើញវិជ្ជមាន (បើការឆ្លងគ្មានរោគសញ្ញាទេ)។** ការស្រាវជ្រាវបានបង្ហា ញថា (ជាភាសាអង់គ្លេស) គម្លាតពេលវេលាកាន់តែយូររវាងការឆ្លងជំងឺ និងការចាក់វ៉ាក់សាំងអាចធ្វើឱ្យប្រព័ន្ធភាពស៊ាំឆ្លើយតបនឹងវ៉ាក់សាំងកាន់តែប្រសើរ។ មិនត្រឹមប៉ុណ្ណោះ គេសង្កេតឃើញថាមានហានិភ័យទាបដែលអាចឆ្លងជំងឺឡើងវិញក្នុងរយៈពេលប៉ុន្មានសប្តាហ៍ទៅប៉ុន្មានខែ បន្ទាប់ពីឆ្លងជំងឺរួច។ គួរតែពិចារណាលើកត្តាបុគ្គលដូចជា ហានិភ័យដែលអាចនឹងឈឺធ្ង ន់ដោយសារជំងឺ COVID-19, កម្រិតឆ្ល ងជំងឺ COVID-19 ក្នុងសហគមន៍ ឬលក្ខណៈនៃប្រភេទវីរុស SARSCoV-2 ដ៏កាចសាហាវ នៅពេលកំណត់ថាត្រូវពន្យារពេលចាក់ 1 ដូសឬអត់ បន្ទាប់ពីឆ្លងជំងឺ។*

DOH 688-003 | December 2023 Khmer ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ doh.information@doh.wa.gov